ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Empress Angkor Resort & Spa
Siem Reap, Kingdom of Cambodia

# កិច្ចព្រមព្រៀង

## រវាងនិយោជក និង និយោជិតក្នុងការព្យួរអាជីវកម្មបណ្តោះអាសន្នរបស់សណ្ឋាគារ

## អេមព្រីសអង្គរ ហូថែល

ខ្ញុំបាទ ស៊ូ សាយ គេទ ប្រុស សញ្ជាតិ ខ្មែរ ជាអ្នកគ្រប់គ្រងទូទៅក្នុងសណ្ឋាគារ **អេមព្រីសអង្គរ ហូថែល** ដែលមានទីតាំងស្ថិតនៅភូមិ កសិកម្ម សង្កាត់ ស្រង៉ែ ក្រុង សៀមរាប ខេត្ត សៀមរាប ដែលជាតំណាងឲ្យ ភាគី "ក"។

និយោជិតទាំងអស់ដែលបំរើការងារនៅក្នុង សណ្ឋាគារ អេមព្រីសអង្គរ ហូថែល ដែលមានទីតាំងស្ថិតនៅភូមិ កសិកម្ម សង្កាត់ ស្រង៉ែ ក្រុង សៀមរាប ខេត្ត សៀមរាប ដែលតំណាងឲ្យ ភាគី "ខ"។

សណ្ឋាគារ **អេមព្រីសអង្គរ ហូថែល** នឹងត្រូវផ្អាកដំណើរការអាជីវកម្មជាបណ្តោះអាសន្ន ចាប់ពីថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២៣ ដោយសារយើងខ្ញុំ កំពុងជួបប្រទះគ្មានភ្ញៀវស្នាក់នៅដែលបណ្តាលមកពីវិបត្តិសកលនៃមេរោគ កូវីត១៩ ជាហេតុធ្វើអោយសណ្ឋាគារ គ្មានប្រាក់ចំណូលដើម្បីប្រតិបត្តការអាជីវកម្មទៀតបាន។

ដូចច្នេះទើបក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ បុគ្គលិកចំនួន ២២ នាក់ ចំពោះការព្យួរកិច្ចសន្យាការងារ នេះដែលក្រុមហ៊ុនបានពិភាក្សាជាមួយថ្នាក់ដឹកនាំ និងប្រតិភូបុគ្គលិករួមទាំងប្រធានក្រុមរហូតដល់មានការព្រមព្រៀងដូចខាងក្រោម៖

**ប្រការមួយ៖** និយោជក (ភាគី"ក") រក្សាកិច្ចសន្យាការងាររបស់បុគ្គលិកនៅដដែល និងអត្ថប្រយោជន៍ផ្សេងៗ ដូចដែលមានចែងក្នុងកិច្ចសន្យាការងាររបស់សណ្ឋាគារ អេមព្រីសអង្គរ ហូថែល

**ប្រការពីរ៖** និយោជិត (ភាគី"ខ") បានព្រមព្រៀងក្នុងការព្យួរកិច្ចសន្យាកាងាររបស់ សណ្ឋាគារអេមព្រីសអង្គរ

**ប្រការ៥៖** និយោជក (ភាគី"ក") ក្នុងកឡុងពេលព្រមព្រៀងព្យួរកិច្ចសន្យាការងារ សណ្ឋាគារបានទូទាត់ប្រាក់បៀវត្សជូនកម្មករនិយោជិកចំនួន ៥០% នៃប្រាក់ឈ្នួលសរុប។

**ប្រការ៦៖** និយោជិក (ភាគី"ខ") ក្នុងកឡុងពេលព្យួរកិច្ចសន្យាការងារ ក្នុងនាមជាតំណាងនិយោជិត និងបុគ្គលិកទាំងអស់ បានយល់ព្រម និងបានដឹងលឺពីការព្យួរកិច្ចសន្យាការងារនេះ និងយល់ព្រមទទួលប្រាក់ឈ្នួល ៥០% ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ ។

ដើម្បីឲ្យប្រាកដ យើងខ្ញុំទាំងពីរភាគី សូមធ្វើការផ្តិតស្នាមមេដៃស្តាំទុកជាភស្តុតាង។

សៀមរាប ថ្ងៃទី ៥ ខែ តុលា ឆ្នាំ២០២៣

ភាគី "ក"

EMPRESS ANGKOR HOTEL

ស៊ូ សាយ

ឈ្មោះ និងស្នាមមេដៃស្តាំភាគី "ខ"

| | | |
|---|---|---|
| ឈ្មោះ សោម ស៊ីណា<br>តួនាទី ប្រធានផ្នែកកក់បន្ទប់ | ឈ្មោះ ឡាច ស្រីនី<br>តួនាទី អនុប្រធានរដ្ឋបាល | ឈ្មោះ អុន រស់ដាលី<br>តួនាទី ប្រធានក្រុមផ្នែកទីផ្សារ |
| ឈ្មោះ ទួន រ៉ាមី<br>តួនាទី អនុប្រធានផ្នែកចុងភៅ | ឈ្មោះ សឿន ស្រីណែត<br>តួនាទី អនុប្រធានផ្នែកកក់បន្ទប់ | ឈ្មោះ ប៊ុត សុកាន់<br>តួនាទី ប្រធានផ្នែកព័ត៌មានវិទ្យា |